វិទ្យាស្ថានគណនេយ្យករ
ជំនាញ និងសវនករកម្ពុជា
KICPAA
Kampuchea Institute of Certified
Public Accountants and Auditors

# អំពី
# វ.គ.ស.ក.

មានការទទួលស្គាល់ និងការជឿទុកចិត្ត

## ជាសមាជិក វ.គ.ស.ក. អ្នកនឹង

- ទទួលស្គាល់ដោយ វ.គ.ស.ក. លើវឌ្ឍនភាពនៃអាជីពរបស់អ្នក
- ទទួលបានការជឿទុកចិត្តពីនិយោជក និងសាធារណជន
- អាចស្នើសុំអាជ្ញាបណ្ណគណនេយ្យ និង/ឬ សវនកម្ម

CONNECT WITH **KICPAA**

រក្សាសិទ្ធិដោយវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (វ.គ.ស.ក.)

បោះពុម្ពលើកទី ១ ឆ្នាំ២០២៤ ដោយ វ.គ.ស.ក.

ព័ត៌មានក្នុងសៀវភៅណែនាំអំពី វ.គ.ស.ក. ផ្អែកលើបទប្បញ្ញត្តិ៖

- អនុក្រឹត្យលេខ ១១៣ អនក្រ. បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ស្តីពី ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- បទបញ្ជាផ្ទៃក្នុងនៃ វ.គ.ស.ក. លេខ ០០៥ / វ.គ.ស.ក. / សសរ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១

រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរករណីបទប្បញ្ញត្តិថ្មីចូលជាធរមាន

អាសយដ្ឋាន៖ ជាន់ទី ៨ អគារ វីត្រាស់ ផ្លូវ ១៦៩ សង្កាត់ វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ កម្ពុជា

# អ្នកឧបត្ថម្ភ

អិន អេ អេស
NAS Co., Ltd

ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី
Deloitte (Cambodia) Co., Ltd.

វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ
Institute of Finance and Accounting

ឡូខលឡាយស៍ ថេក សូលូសិន ឯ.ក
Localize Tech Solution Co., Ltd.

បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក
Baker Tilly (Cambodia) Co., Ltd.

ខេឌី ខនសាល់ធេន ឯ.ក
KD Consultants Company Limited

បារុន (ខេមបូឌា) អឹខោនធីង & ខនសាល់ធីង ឯ.ក
Barun (Cambodia) Accounting & Consulting Co., Ltd.

វីប៊ីធី អេន ផាតនើរ ឯ.ក
VBT and Partners Co., Ltd.

សំរិទ្ធ អឹខោនធីង អេន មេនេចម៉ិន ឯ.ក
Samrith Accounting and Management Co., Ltd.

អេស អិម គ្លូបិល អឹខោនធីង & ខនសាល់ធីង
S M Global Accounting & Consulting Co., Ltd.

រៀល ប៊ីហ្សនេស ខនសាល់ថេសិន
Real Business Consultation Co., Ltd.

អេនដ្រូ & ហ្វីលីព អឹខោនធីង (អេ & ភី អឹខោនធីង)
Andrew & Philip Accounting Co., Ltd.

រីនដា អិល អិល ខេ ជី (ខេមបូឌា)
Reanda L L K G (Cambodia) Co., Ltd.

ប្លូ ឆាធើរ អឹខោនថិន អេន អឌីតធ័រ ឯ.ក
Blue Chartered Accountants and Auditors Co., Ltd.

ខេមវីន ហ្វាយនែនសល អែតវ៉ាយហ្សរី ឯ.ក
Camwin Financial Advisory Co., Ltd.

ភី អេ ធី ប្រហ្វេសិនណល លីមីធីត
P A T Professional Limited.

- អេកូវីស វីអេសឌីខេ & ផាតនើរ ឯ.ក
  Ecovis VSDK & Partners Co., Ltd.
- អេ-អិចសឺឡិន ខនសាល់ធេនស៊ី ឯ.ក
  A-Xcellent Consultancy Co., Ltd.
- អេចអិលប៊ី អឌីត & ផាតនើរ ឯ.ក
  HLB Audit & Partners Co., Ltd.
- ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
  Grant Thornton (Cambodia) Limited.
- ខេមបូឌាន អ៊ិនវេសមិន មេនេចមិន អ៊ីខោនធីង សឺវីស ឯ.ក
  Cambodian Investment Management Accounting Services Co., Ltd.
- ឡូចន្ទ & ខូ (ខេមបូឌា) ឯ.ក
  Lochan & Co (Cambodia) Company Limited.
- អេសឌី វីហ្សិន ខេម ឯ.ក
  SD Vision Cam Co., Ltd.
- យ៉ុងអាន អ៊ិនធើណេសិនណល ខនសាល់ធីង ឯ.ក
  Yongan International Consulting Co., Ltd.
- ជេភី-ខេម ជីនហ្សៃ ខន់សាល់ធីង ឯ.ក
  JP-CAM Jinzai Consulting Co., Ltd.
- អាល់នីសុន អូឌីធីង អេន ខនសាល់ធីង
  Allnison Auditing and Consulting Co., Ltd.
- ខេ ភី អឹម ជី ខេមបូឌា
  KPMG Cambodia Ltd.
- ប៊ី ឌី អូ (ខេមបូឌា) លីមីធីត
  BDO (Cambodia) Limited.
- ឡា ប៉េ ផាតនើរ & អាសូស៊ីអេត ឯ.ក
  La Paix Partners & Associates Co., Ltd.
- ខេម អ៊ីខោនធីង & ថាក សឺវីស ឯ.ក
  CAM Accounting & Tax Service Company Limited.
- ដូណាស្កូ & ខមភេនី លីមីធីត
  Donasco & Company Ltd.
- វូរី អេខោនធីង (ខេមបូឌា) ឯ.ក
  Woori Accounting Co., Ltd.

# មាតិកា


| | |
|---|---|
| ប្រវត្តិ វ.គ.ស.ក. ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល | ២ |
| ច្បាប់ និងបទប្បញ្ញត្តិ វ.គ.ស.ក. | ៣ |
| តើ វ.គ.ស.ក. ជានរណា ? | ៣ |
| រចនាសម្ព័ន្ធរបស់ វ.គ.ស.ក. | ៤ |
| ក្រុមប្រឹក្សាភិបាលរបស់ វ.គ.ស.ក. | ៥ |
| គណៈកម្មការរបស់ វ.គ.ស.ក. | ៦ |
| លេខាធិការដ្ឋានរបស់ វ.គ.ស.ក. | ៨ |
| សមាជិកភាព | ៩ |
| ការអប់រំ និងបណ្តុះបណ្តាល | ១៧ |
| សមាជិកជាប្រភេទក្រុមហ៊ុន | ១៩ |
| សមាជិកជាប្រភេទរូបវន្តបុគ្គល | ២៤ |

## ប្រវត្តិ វ.គ.ស.ក.

វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (វ.គ.ស.ក.) គឺជាស្ថាប័នមិនស្វែងរកប្រាក់ចំណេញ និងឯករាជ្យក្នុងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតែមួយគត់នៅកម្ពុជា ដែលបានបង្កើតឡើងនៅឆ្នាំ២០០៣ ដោយច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ (២០០២) និងត្រូវបានជំនួសដោយច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដែលបានបង្កើតក្នុងឆ្នាំ២០១៦។ វិទ្យាស្ថានត្រូវបានបង្កើតឡើង (១)ដើម្បីការពារផលប្រយោជន៍សាធារណៈនិងវិជ្ជាជីវៈ (២)គ្រប់គ្រងសមាជិករបស់ខ្លួនតាមរយៈការអភិវឌ្ឍសមត្ថភាពជំនាញ (៣)ចូលរួមជំរុញការអនុវត្តអនុលោមភាពនៃស្តង់ដា ក្រមសីលធម៌វិជ្ជាជីវៈ វិធាននិងបទប្បញ្ញត្តិនានា និង (៤)បង្កើតនិងគ្រប់គ្រងកម្មវិធីសិក្សានិងការប្រឡងគណនេយ្យករជំនាញនិងសវនករ។

## ចក្ខុវិស័យ

ជាស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតែមួយគត់ ដែលមានការទទួលស្គាល់និងជឿទុកចិត្តនៅកម្ពុជា។

## បេសកកម្ម

ដើម្បីរក្សាឱ្យបាននូវប្រយោជន៍សាធារណៈតាមរយៈនិយ័តកម្ម និងការអប់រំដល់គណនេយ្យករជំនាញ ឱ្យស្របតាមស្តង់ដាវិជ្ជាជីវៈនិងក្រមសីលធម៌ខ្ពស់ និងផ្តល់នូវទំនុកចិត្តជូនសាធារណជនប្រកបដោយវិជ្ជាជីវៈ។

## តម្លៃស្នូល

**ភាពត្រឹមត្រូវ និង យុត្តិធម៌៖** វិទ្យាស្ថានប្តេជ្ញាក្នុងការយកចិត្តទុកដាក់ចំពោះសមាជិកទាំងអស់ដោយយុត្តិធម៌ មិនលំអៀង និងស្អិតស្អែរ

**គណនេយ្យភាព៖** វិទ្យាស្ថានទទួលខុសត្រូវចំពោះ សកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន

**សុចរិតភាព៖** វិទ្យាស្ថានប្រឹងប្រែងបំពេញការងារប្រកបដោយភាពស្មោះត្រង់ ក្រមសីលធម៌ និងវិជ្ជាជីវៈ

**ការគោរព៖** វិទ្យាស្ថានធ្វើការឆ្លើយតប និងគិតគូរដោយក្តីគោរពចំពោះសមាជិកនិងសាធារណជនទាំងអស់។

## ច្បាប់ និងបទប្បញ្ញត្តិ វ.គ.ស.ក.













## តើ វ.គ.ស.ក.ជានរណា?

**១**

ជាស្ថាប័នវិជ្ជាជីវៈ
គណនេយ្យ និងសវនកម្ម
តែមួយគត់នៅ
ប្រទេសកម្ពុជា

**២**

ជាសមាជិកចម្បង
របស់ AFA
(២០០៣)

**៣**

ជាសមាជិកសមាគត
របស់ IFAC
(២០០៨)

# រចនាសម្ព័ន្ធរបស់ វ.គ.ស.ក.

## គណៈប្រឹក្សាភិបាល

**ក្រុមប្រឹក្សាភិបាល**

- គណៈកម្មការ<br>ចុះឈ្មោះនិងសមាជិកភាព
- គណៈកម្មការ<br>បច្ចេកទេស
- គណៈកម្មការ<br>អប់រំ និងបណ្តុះបណ្តាល
- គណៈកម្មការ<br>ស៊ើបអង្កេតនិងវិន័យ

## គណៈប្រតិបត្តិ

**នាយកប្រតិបត្តិ**

- នាយកដ្ឋាន<br>សមាជិកភាព និង<br>ទំនាក់ទំនងអន្តរជាតិ
- នាយកដ្ឋាន<br>អប់រំ បណ្តុះបណ្តាល<br>និងស្រាវជ្រាវ
- នាយកដ្ឋាន<br>រដ្ឋបាលនិងបុគ្គលិក
- នាយកដ្ឋាន<br>គណនេយ្យនិងហិរញ្ញវត្ថុ
- នាយកដ្ឋាន<br>គ្រប់គ្រងបច្ចេកវិទ្យា ព័ត៌មានវិទ្យា<br>និងការផ្សព្វផ្សាយ



## ក្រុមប្រឹក្សាភិបាលរបស់ វ.គ.ស.ក.

ក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. ដឹកនាំដោយប្រធាន ១ (មួយ) រូប និងអនុប្រធាន ១ (មួយ) រូបជាជំនួយការ។ ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសចេញពីសមាជិក វ.គ.ស.ក. តាមរយៈនៃការបោះឆ្នោតនៅក្នុងមហាសន្និបាតលើកលែងតែសមាសភាពដែលជា តំណាងពីស្ថាប័នដូចបានចែងក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ។ ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ វ.គ.ស.ក. ត្រូវបានតែងតាំងដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. មានមុខងារនិងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ វ.គ.ស.ក.
- ពិនិត្យនិងអនុម័តលើសេចក្តីព្រាងក្រមសីលធម៌វិជ្ជាជីវៈគណនេយ្យករនិងសវនករ
- ពិនិត្យនិងអនុម័តវិធានគ្រប់គ្រងនានារបស់ វ.គ.ស.ក.
- ពិនិត្យនិងអនុម័តលើគោលនយោបាយ និងវិធានការនានាដែលរៀបចំឡើងដោយលេខាធិការដ្ឋាននៃ វ.គ.ស.ក.
- ពិនិត្យនិងអនុម័តលើផែនការយុទ្ធសាស្ត្រនិងគម្រោងថវិកាប្រចាំឆ្នាំដែលរៀបចំឡើងដោយលេខាធិការដ្ឋាននៃ វ.គ.ស.ក.
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការថវិកាប្រចាំឆ្នាំរបស់ វ.គ.ស.ក.
- ផ្តល់ការយល់ព្រមលើរបាយការណ៍លទ្ធផលការងារនិងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ វ.គ.ស.ក.
- សម្រេចតែងតាំង ព្យួរការងារ និងបញ្ឈប់ការងាររបស់នាយកប្រតិបត្តិ និងកំណត់លាភការផ្សេងៗ របស់នាយកប្រតិបត្តិ
- សម្រេចលើគោលការណ៍ជ្រើសរើសបុគ្គលិករបស់លេខាធិការដ្ឋាននៃ វ.គ.ស.ក.
- សម្រេចលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់លេខាធិការដ្ឋាននៃ វ.គ.ស.ក.
- ពិនិត្យនិងសម្រេចលើការបង្កើតគណៈកម្មការ អនុគណៈកម្មការ និងក្រុមការងារនានា ស្របតាមតម្រូវការចាំបាច់របស់ វ.គ.ស.ក.
- រាយការណ៍ជាលាយលក្ខណ៍អក្សរអំពីផែនការ គម្រោងថវិកា និងលទ្ធផលនៃការអនុវត្តផែនការនិងថវិកាមក ក.ជ.គ. និង
- ពិនិត្យនិងសម្រេចលើសំណើបើកការិយាល័យតំណាង និង/ឬសាខាតាមបណ្តាខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា។

## គណៈកម្មការរបស់ វ.គ.ស.ក.

វ.គ.ស.ក. មានគណៈកម្មការចំនួន ៤ (បួន) ជាសេនាធិការ ដូចខាងក្រោម៖

១) គណៈកម្មការចុះឈ្មោះនិងសមាជិកភាព

២) គណៈកម្មការបច្ចេកទេស

៣) គណៈកម្មការអប់រំ និងបណ្តុះបណ្តាល

៤) គណៈកម្មការស៊ើបអង្កេតនិងវិន័យ។

### គណៈកម្មការ ចុះឈ្មោះនិងសមាជិកភាព

**គណៈកម្មការចុះឈ្មោះនិងសមាជិកភាពមានភារកិច្ចដូចខាងក្រោម៖**

- ពិនិត្យនិងសម្រេចលើលក្ខខណ្ឌតម្រូវនិងគុណវុឌ្ឍិសម្រាប់ចូលជាសមាជិករបស់ វ.គ.ស.ក.
- ពិនិត្យនិងសម្រេចផ្តល់សមាជិកភាពដល់រូបវន្តបុគ្គល និង/ឬ នីតិបុគ្គលទាំងឡាយណាដែលមានបំណងប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យនិងសម្រេចលើការព្យួរ និងការដកហូតសមាជិកភាពនៃសមាជិករបស់ វ.គ.ស.ក.
- ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិករបស់ វ.គ.ស.ក.
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. ប្រគល់ជូន។

### គណៈកម្មការ បច្ចេកទេស

**គណៈកម្មការបច្ចេកទេសមានភារកិច្ចដូចខាងក្រោម៖**

- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាដែលរៀបចំដោយក្រុមប្រឹក្សាជាតិគណនេយ្យ
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើសេចក្តីព្រាងស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងការអះអាងដែលបានចេញផ្សាយ ដោយក្រុមប្រឹក្សាជាតិគណនេយ្យ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ សហព័ន្ធគណនេយ្យករអន្តរជាតិ និងស្ថាប័នជាតិនិងអន្តរជាតិផ្សេងៗទៀត
- ផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសពាក់ពន្ធ័នឹងគណនេយ្យ សវនកម្ម និងការអះអាង ពន្ធដារ ក្រមសីលធម៌ អភិបាលកិច្ច និងការងារពាក់ព័ន្ធផ្សេងទៀត
- អនុវត្តភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. ប្រគល់ជូន។

## គណៈកម្មការ អប់រំ និងបណ្តុះបណ្តាល

**គណៈកម្មការអប់រំនិងបណ្តុះបណ្តាលមានភារកិច្ចដូចខាងក្រោម៖**

- រៀបចំនិងអនុវត្តតាមផែនការយុទ្ធសាស្ត្រនិងទិសដៅការងារដែលបានដាក់ចេញដោយ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- រៀបចំ អភិវឌ្ឍ និងគ្រប់គ្រងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យនិងកម្មវិធីសិក្សាផ្សេងៗទៀត ស្របតាមតម្រូវការនិងការអភិវឌ្ឍនៃវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា
- រៀបចំ និងគ្រប់គ្រងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យនិងកម្មវិធីសិក្សាផ្សេងៗទៀត របស់ វ.គ.ស.ក.
- អនុវត្តភារកិច្ចផ្សេងៗដែល ក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. ប្រគល់ជូន។

## គណៈកម្មការ ស៊ើបអង្កេតនិងវិន័យ

**គណៈកម្មការស៊ើបអង្កេតនិងវិន័យមានភារកិច្ចដូចខាងក្រោម៖**

- ទទួលនិងដោះស្រាយបណ្តឹងពីតតិយជនពាក់ព័ន្ធនឹងសមាជិករបស់ខ្លួន
- បណ្តឹងឬវិវាទរវាងសមាជិកផងគ្នា
- ការមិនគោរពតាមក្រមសីលធម៌របស់សមាជិក
- ពិនិត្យ វាយតម្លៃនិងដាក់ពិន័យលើសមាជិកដែលបានប្រព្រឹត្តខុស និង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. ប្រគល់ជូន។



## លេខាធិការដ្ឋានរបស់ វ.គ.ស.ក.

វ.គ.ស.ក. ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការរដ្ឋបាល និងបច្ចេកទេសអចិន្ត្រៃយ៍។ លេខាធិការដ្ឋានត្រូវដឹកនាំដោយនាយកប្រតិបត្តិ ១ (មួយ) រូប ដែលត្រូវជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក.។ នាយកប្រតិបត្តិទទួលខុសត្រូវលើការគ្រប់គ្រងនិង សម្របសម្រួលកិច្ចការប្រតិបត្តិប្រចាំថ្ងៃរបស់ វ.គ.ស.ក.។

**លេខាធិការដ្ឋាននៃ វ.គ.ស.ក. មានមុខងារនិងភារកិច្ចដូចខាងក្រោម៖**

- រៀបចំគ្រប់គ្រង និងសម្របសម្រួលការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់ វ.គ.ស.ក.
- រៀបចំកិច្ចប្រជុំរបស់ វ.គ.ស.ក.
- រៀបចំនិងអនុវត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គម្រោងថវិកាប្រចាំឆ្នាំ និងផែនការនានា របស់ វ.គ.ស.ក.
- រៀបចំសេចក្តីព្រាងគោលនយោបាយ និងវិធាននានាសម្រាប់ការគ្រប់គ្រង វ.គ.ស.ក.
- លើកសំណើសុំបើកការិយាល័យនៅតាម បណ្តាខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- សហការយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានឧត្តមសិក្សាជាតិ និងអន្តរជាតិដើម្បីជំរុញ ការអនុវត្តកម្មវិធីសិក្សាគណនេយ្យស្រប តាមបទដ្ឋានអន្តរជាតិ
- ធ្វើជាតំណាង វ.គ.ស.ក. ក្នុងទំនាក់ទំនងជាមួយតតិយជន ដូចជា ស្ថាប័ននិយ័តកជាតិ ស្ថាប័នវិជ្ជាជីវៈគណនេយ្យក្នុងតំបន់ និងអន្តរជាតិដើម្បីលើកកម្ពស់ និងការពារវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា
- រាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីលទ្ធផលនៃការអនុវត្តផែនការ និងថវិកាប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រុមប្រឹក្សាភិបាលរបស់ វ.គ.ស.ក.
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានក្រុមប្រឹក្សាភិបាល នៃ វ.គ.ស.ក.ប្រគល់ជូន។

## សមាជិកភាព

### មូលហេតុដែលត្រូវចូលជាសមាជិក វ.គ.ស.ក.

**១ អាជ្ញាបណ្ណ**

ជាសមាជិក វ.គ.ស.ក. អ្នកអាចស្នើសុំអាជ្ញាបណ្ណគណនេយ្យនិងសវនកម្មពីនិយ័តករគណនេយ្យនិងសវនកម្ម ន.គ.ស.

**២ ទទួលស្គាល់ និង ជឿទុកចិត្ត**

ទទួលស្គាល់ និងជឿទុកចិត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ និយ័តករគណនេយ្យនិងសវនកម្ម និងបង្ហាញឈ្មោះរបស់អ្នកនៅលើគេហទំព័រ វ.គ.ស.ក.

**៣ កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD)**

ជាសមាជិក វ.គ.ស.ក. ទទួលបាននូវ វគ្គបណ្តុះបណ្តាលនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) និងមានផ្តល់ ជាវិញ្ញាបនបត្រសម្រាប់បង្កើនគុណតម្លៃវិជ្ជាជីវៈរបស់អ្នក

**៤ បញ្ចុះតម្លៃ/ឥតគិតថ្លៃ**

ទទួលបានការបញ្ចុះតម្លៃ ឬឥតគិតថ្លៃលើការចូលរួមក្នុង សិក្ខាសាលា ការបណ្តុះបណ្តាល និងព្រឹត្តិការណ៍ផ្សេងទៀតដែលរៀបចំដោយ វ.គ.ស.ក.

**៥ បច្ចុប្បន្នភាព**

បានធ្វើបច្ចុប្បន្នភាពលើបញ្ហាបច្ចុប្បន្ន ឬបញ្ហាប្រឈមដែលអាចកែលម្អអង្គភាពរបស់អ្នកសម្រាប់ពេលអនាគតឱ្យកាន់តែប្រសើរ

**៦ ទំនាក់ទំនង**

ពង្រីកបណ្តាញទំនាក់ទំនងរបស់អ្នក (network) និងពង្រឹងទំនាក់ទំនងជាមួយសមាជិក និយ័តករសំខាន់ៗ និងភាគីពាក់ព័ន្ធ តាមរយៈកម្មវិធីដែលបង្កើតឡើងដោយ វ.គ.ស.ក.

**៧ ចែករំលែក**

អ្នកនឹងទទួលបានព័ត៌មានថ្មីៗអំពីការប្រែប្រួលនៃច្បាប់/បទប្បញ្ញត្តិ និងបញ្ហាបច្ចេកទេស ដែលប៉ះពាល់ដល់កាតព្វកិច្ចផ្លូវច្បាប់ ការអនុលោម និងស្តង់ដានានាតាមរយៈការចែករំលែកអត្ថបទវីដេអូ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់ វ.គ.ស.ក.ជាដើម

**៨ ប្រយោជន៍ដល់សង្គម**

អតិរេកដែលបានមកពីវិភាគទាននឹងត្រូវបានចែករំលែកសម្រាប់ជាប្រយោជន៍ដល់សង្គម និងគាំទ្រក្នុងវគ្គបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា

## អាជ្ញាបណ្ណ



## ទទួលស្គាល់ និង ជឿទុកចិត្ត





## កម្មវិធីអភិវឌ្ឍនវិជ្ជាជីវៈបន្ត (CPD)








## បញ្ចុះតម្លៃ/ឥតគិតថ្លៃ










## ទំនាក់ទំនង





## បច្ចុប្បន្នភាព




## ប្រយោជន៍ដល់សង្គម





## ចែករំលែក






## ក្រោយពេលក្លាយជាសមាជិក

អ្នកនឹងក្លាយជាគណនេយ្យករ ឬសវនករដែលមានការទទួលស្គាល់និងជឿជាក់បានពីនិយោជកក៏ដូចជាសាធារណជន អាចស្នើសុំអាជ្ញាបណ្ណគណនេយ្យ និង/ឬ សវនកម្ម។

### បង្ហាញឈ្មោះនៅលើគេហទំព័រ វ.គ.ស.ក.



### ទទួលវិញ្ញាបនបត្រសមាជិកភាពពី វ.គ.ស.ក.




### សកម្មភាពនៃការទទួលវិញ្ញាបនបត្រសមាជិកភាព








## តើសមាជិក វ.គ.ស.ក. មានប៉ុន្មានប្រភេទ ?

១ សមាជិកជាប្រភេទក្រុមហ៊ុន

២ សមាជិកជាប្រភេទរូបវន្តបុគ្គល

- សមាជិកកិត្តិយស
- សមាជិកសមាគត
- សមាជិកសកម្ម
- សមាជិកបម្រុង
- សមាជិកចូលរួម

## លក្ខខណ្ឌចូលជាសមាជិក

### ១ សមាជិកជាប្រភេទក្រុមហ៊ុន

ក្រុមហ៊ុនដែលមានបំណងចុះឈ្មោះជាសមាជិក វ.គ.ស.ក. ត្រូវមានលក្ខខណ្ឌនិងគុណវុឌ្ឍិដូចខាងក្រោម៖

ក. បំពេញនូវបែបបទសុំចុះឈ្មោះជាសមាជិក

ខ. ជាក្រុមហ៊ុនដែលចុះឈ្មោះក្រោមក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្នុងទម្រង់ណាមួយ៖

- ក្នុងករណីម្ចាស់ភាគហ៊ុនជារូបវន្តបុគ្គល៖
  ជាក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្នុងទម្រង់ណាមួយ ដែលមានម្ចាស់ភាគហ៊ុនជា សមាជិកសមាគត ឬសមាជិកចូលរួម ឬសមាជិកសកម្មជាគណនេយ្យករជំនាញ ឬសមាជិកសកម្មជាសវនករប្រតិស្រុតរបស់ វ.គ.ស.ក. យ៉ាងតិច ១(មួយ) រូប កាន់កាប់ភាគហ៊ុនយ៉ាងតិច ៥០% ឬ
- ក្នុងករណីម្ចាស់ភាគហ៊ុនជានីតិបុគ្គល ៖
  ជាក្រុមហ៊ុនដែលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្នុងទម្រង់ណាមួយ ដែលមានសមាសភាពក្រុមប្រឹក្សាភិបាលយ៉ាងតិច ៥០% ជាសមាជិកសមាគត ឬសមាជិកចូលរួម ឬសមាជិកសកម្មជាគណនេយ្យករជំនាញ ឬសមាជិកជាសវនករប្រតិស្រុតរបស់ វ.គ.ស.ក.

គ. កម្មវត្ថុអាជីវកម្មចម្បងដែលមាននៅក្នុងលក្ខន្តិកៈក្រុមហ៊ុនត្រូវតែជាសេវាកម្មគណនេយ្យ និង/ឬសវនកម្ម

ឃ. ប័ណ្ណប៉ាតង់ និងវិញ្ញាបនបត្រអាករលើតំលៃបន្ថែមត្រូវតែមានឈ្មោះសមាជិកសមាគត ឬសមាជិកចូលរួម ឬសមាជិកសកម្ម ជាគណនេយ្យករជំនាញ ឬសមាជិកសកម្មជាសវនករប្រតិស្រុតជាម្ចាស់សហគ្រាស

ង. ប្រវត្តិរូបរបស់ភាគហ៊ុនិក និងសមាជិកក្រុមប្រឹក្សាភិបាល

ច. បង្កាន់ដៃបង់ថ្លៃដាក់ពាក្យសុំចូលជាសមាជិក (ច្បាប់ថតចម្លង)។

ក្រុមហ៊ុនដែលជាសមាជិករបស់ វ.គ.ស.ក. អាចប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្ម ត្រូវបំពេញនូវលក្ខខណ្ឌតម្រូវនានាដែលមានកំណត់នៅក្នុងប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងវិជ្ជាជីវៈសវនកម្ម ព្រមទាំង វិធាននៃសមាជិកភាពរបស់ វ.គ.ស.ក. ។

## ២ សមាជិកជាប្រភេទរូបវន្តបុគ្គល

### សមាជិកសកម្មជាសវនករប្រតិស្រុត

ក. បំពេញនូវបែបបទសុំចុះឈ្មោះជាសមាជិក

ខ. សញ្ញាបត្រគណនេយ្យករជំនាញ (CPA/ACCA/CA/other equivalent) ដែលទទួលស្គាល់ដោយ វ.គ.ស.ក.

គ. បទពិសោធការងារយ៉ាងតិច ៣ (បី) ឆ្នាំពាក់ព័ន្ធនឹងវិជ្ជាជីវៈសវនកម្មជាមួយក្រុមហ៊ុនសវនកម្មដែលជាសមាជិករបស់ វ.គ.ស.ក. ឬក្រុមហ៊ុនសវនកម្មស្របច្បាប់នៅបរទេសដែលទទួលស្គាល់ដោយ វ.គ.ស.ក. ក្នុងអំឡុងពេល ៨ (ប្រាំបី) ឆ្នាំចុងក្រោយគិតត្រឹមពេលចូលជាសមាជិក។

ឃ. លិខិតបញ្ជាក់ភាពជាសមាជិក (Certificate of Good Standing) ពីស្ថាប័នវិជ្ជាជីវៈនៅក្រៅប្រទេសរបស់ខ្លួន (សម្រាប់ជនបរទេស)

ង. ប្រវត្តិរូប (C.V) ដែលមានភ្ជាប់មកជាមួយនឹងលិខិតបញ្ជាក់ការងារពីក្រុមហ៊ុនដែលលោកលោកស្រីធ្លាប់បានធ្វើការ និងកំពុងធ្វើការ

ច. លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ

ឆ. រូបថត ៤ x ៦ ចំនួន ១សន្លឹក

ជ. បង្កាន់ដៃបង់ថ្លៃដាក់ពាក្យសុំចូលជាសមាជិក

### សមាជិកសកម្មជាគណនេយ្យករជំនាញ

ក. បំពេញនូវបែបបទសុំចុះឈ្មោះជាសមាជិក

ខ. សញ្ញាបត្រគណនេយ្យករជំនាញ (CPA/ACCA/CA/other equivalent) ដែលទទួលស្គាល់ដោយ វ.គ.ស.ក.

គ. បទពិសោធការងារយ៉ាងតិច ៣ (បី) ឆ្នាំពាក់ព័ន្ធនឹងវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម ជាមួយក្រុមហ៊ុន ដែលជាសមាជិករបស់ វ.គ.ស.ក. ឬក្រុមហ៊ុនគណនេយ្យ ឬក្រុមហ៊ុនសវនកម្មស្របច្បាប់នៅបរទេសដែលទទួលស្គាល់ដោយ វ.គ.ស.ក. ក្នុងអំឡុងពេល ៨ (ប្រាំបី) ឆ្នាំចុងក្រោយគិតត្រឹមពេលចូលជាសមាជិក។

ឃ. លិខិតបញ្ជាក់សមាជិកភាព (Certificate of Good Standing) ពីស្ថាប័នវិជ្ជាជីវៈរបស់ខ្លួន (សម្រាប់ជនបរទេស)

ង. ប្រវត្តិរូប (C.V) ដែលមានភ្ជាប់មកជាមួយនឹងលិខិតបញ្ជាក់ការងារពីក្រុមហ៊ុនដែលលោក លោកស្រីធ្លាប់បានធ្វើការ និងកំពុងធ្វើការ

ច. លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ

ឆ. រូបថត ៤ x ៦ ចំនួន ១សន្លឹក

ជ. បង្កាន់ដៃបង់ថ្លៃដាក់ពាក្យសុំចូលជាសមាជិក

## សមាជិកចូលរួម

ក. បំពេញនូវបែបបទសុំចុះឈ្មោះជាសមាជិក

ខ. បានបញ្ចប់កម្មវិធីសិក្សាគណនេយ្យករជំនាញជាតិ ឬមានសញ្ញាបត្រគណនេយ្យករជំនាញពីបរទេសដែលទទួលស្គាល់ដោយ វ.គ.ស.ក. ឬ

គ. ជារូបវន្តបុគ្គលដែលបច្ចុប្បន្នជានាយក ឬអ្នកគ្រប់គ្រងជាន់ខ្ពស់ទទួលបន្ទុកកិច្ចការគណនេយ្យ ឬហិរញ្ញវត្ថុ ឬ

ឃ. ជារូបវន្តបុគ្គលដែលកំពុងបង្រៀនមុខវិជ្ជាគណនេយ្យ ហិរញ្ញវត្ថុ នៅតាមគ្រឹះស្ថានសិក្សានានានៅក្នុងព្រះរាជាណាចក្រកម្ពុជាជាមួយនឹងបទពិសោធបង្រៀនយ៉ាងតិច ៧ (ប្រាំពីរ)ឆ្នាំ ឬ

ង. ជារូបវន្តបុគ្គលដែលកំពុងធ្វើការងារគណនេយ្យ ឬហិរញ្ញវត្ថុជាមួយបទពិសោធយ៉ាងតិច៧ (ប្រាំពីរ) ឆ្នាំ

ច. ប្រវត្តិរូប (C.V) ដែលមានភ្ជាប់មកជាមួយនឹងលិខិតបញ្ជាក់ការងារពីក្រុមហ៊ុនដែលលោក លោកស្រីធ្លាប់បានធ្វើការ និងកំពុងធ្វើការ

ឆ. លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ

ឈ. រូបថត ៤ x ៦ ចំនួន១សន្លឹក

ញ. បង្កាន់ដៃបង់ថ្លៃដាក់ពាក្យសុំចូលជាសមាជិក

## សមាជិកសមាគត

ក. បំពេញនូវបែបបទសុំចុះឈ្មោះជាសមាជិក

ខ. សញ្ញាបត្របច្ចេកទេសគណនេយ្យ សញ្ញាបត្របរិញ្ញាបត្ររង ឬ សញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យ ឡើងទៅ និងទទួលស្គាល់ដោយ វ.គ.ស.ក. និង

គ. បទពិសោធយ៉ាងតិច៣ (បី) ឆ្នាំពាក់ព័ន្ធនឹង គណនេយ្យ សវនកម្ម ឬហិរញ្ញវត្ថុ (បទពិសោធបង្រៀន និង/ឬធ្វើការងារតាមស្ថាប័ន សហគ្រាស ឬអង្គភាពនានា)

ឃ. ប្រវត្តិរូប (C.V) ដែលមានភ្ជាប់មកជាមួយនឹងលិខិតបញ្ជាក់ការងារពីក្រុមហ៊ុន

ង. លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ
ច. រូបថត ៤ x៦ ចំនួន១សន្លឹក
ឆ. បង្កាន់ដៃបង់ថ្លៃដាក់ពាក្យសុំចូលជាសមាជិក

**សមាជិកបម្រុង**

ក. បំពេញនូវបែបបទសុំចុះឈ្មោះជាសមាជិក
ខ. ជាបុគ្គលដែលកំពុងសិក្សាក្នុងកម្មវិធីគណនេយ្យករជំនាញជាតិ កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ កម្មវិធីសិក្សាគណនេយ្យជំនាញក្រោមកម្មវិធីប្រឡងរួមគ្នា ឬកម្មវិធីគណនេយ្យករជំនាញដទៃទៀតដែលទទួល ស្គាល់ដោយ វ.គ.ស.ក. ឬជាបុគ្គលដែលកំពុងសិក្សាជំនាញគណនេយ្យ ឬហិរញ្ញវត្ថុ ឬពន្ធដារ នៅគ្រឹះស្ថាន សិក្សានានាដែលទទួលស្គាល់ដោយ វ.គ.ស.ក.
គ. ប្រវត្តិរូប (C.V)
ឃ. លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ
ង. រូបថត ៤ x ៦ ចំនួន១សន្លឹក
ច. បង្កាន់ដៃបង់ថ្លៃដាក់ពាក្យសុំចូលជាសមាជិក

## តើខ្ញុំគួរធ្វើដូចម្តេចដើម្បីទទួលបានអាជ្ញាបណ្ណផ្តល់សេវាកម្មគណនេយ្យ និង/ឬសវនកម្ម ?

អនុលោមតាម **[អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តិទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម]** រូបវន្តបុគ្គល និង នីតិបុគ្គលអាចប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬ សវនកម្មបានលុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ វ.គ.ស.ក.។ បន្ទាប់មក អ្នកនឹងទទួលបានវិញ្ញាបនបត្រសមាជិកភាពដើម្បីដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពី ន.គ.ស.។

# ដំណើរការនៃការស្នើសុំសមាជិកភាព

## ១ ការសាកសួរព័ត៌មាន

ទាក់ទងមកមន្ត្រីផ្នែកសមាជិកភាព ឬចូល ទៅកាន់គេហទំព័រ ( www.kicpaa.org ) ដើម្បីទទួលបានព័ត៌មាន និងពាក្យស្នើសុំ

## ២ ការដាក់ពាក្យ

បំពេញនិងដាក់ពាក្យស្នើសុំដោយភ្ជាប់ជាមួយឯកសារតម្រូវនានា មកកាន់ ការិយាល័យ វ.គ.ស.ក.

ជាន់ទី ៨ អគារ វីត្រាស់ ផ្លូវ ១៦៩ សង្កាត់ វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ កម្ពុជា

## ៣ ការបង់ថ្លៃដាក់ពាក្យ

ក្នុងរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការ មន្ត្រី វ.គ.ស.ក. នឹងផ្តល់ព័ត៌មានជូនបេក្ខជនវិញ ហើយ វ.គ.ស.ក. តម្រូវឱ្យអ្នកបង់ថ្លៃពាក្យស្នើសុំសមាជិកភាព។

## ៤ ការផ្ទៀងផ្ទាត់ព័ត៌មាន

វ.គ.ស.ក. ត្រូវការរយៈពេលប្រមាណ ១ ខែ ឬច្រើនជាងនេះ ដើម្បីធ្វើការផ្ទៀងផ្ទាត់ព័ត៌មាន។

## ៥ ការប្រកាសលទ្ធផល

បន្ទាប់ពីការផ្ទៀងផ្ទាត់ត្រូវបានបញ្ចប់ ពាក្យស្នើសុំរបស់អ្នកនឹងត្រូវបានវាយតម្លៃដោយគណៈកម្មការចុះឈ្មោះ និងសមាជិកភាព ហើយលទ្ធផលផ្លូវការនឹងត្រូវបានផ្ញើជូនអ្នកតាមរយៈអ៊ីមែល។

**ចំណាំ៖** ប្រសិនបើអ្នកមានចម្ងល់អំពីដំណើរការចុះឈ្មោះ ឬឯកសារដែលត្រូវការ សូមធ្វើការទាក់ទងមកកាន់មន្ត្រីសមាជិកភាព វ.គ.ស.ក. ដែលតែងតែស្វាគមន៍ក្នុងការប្រឹក្សាជាមួយអ្នកជានិច្ច។

H/P: 023 23 17 07 | ទូរស័ព្ទ៖ 077 24 17 07 | អ៊ីមែល៖ membership@kicpaa.org

# ការអប់រំ និងបណ្តុះបណ្តាល

## កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD Program)

### វគ្គបណ្តុះបណ្តាលជាទូទៅ

- ១ សិក្ខាសាលាអនឡាញស្តីពី ក្រមសីលធម៌វិជ្ជាជីវៈ
- ២ សិក្ខាសាលាអនឡាញស្តីពី រលកនៃការវាយប្រហារពីសាយប័រលើគ្រឹះស្ថានហិរញ្ញវត្ថុ
- ៣ សិក្ខាសាលាអនឡាញស្តីពី ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យមដោយផ្តោតលើឧបករណ៍ហិរញ្ញវត្ថុ
- ៤ សិក្ខាសាលាអនឡាញស្តីពី បច្ចុប្បន្នភាពពន្ធដារ
- ៥ សិក្ខាសាលាអនឡាញស្តីពី ការផ្ទេរថ្លៃ
- ៦ សិក្ខាសាលាអនឡាញស្តីពី ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ S1 S2
- ៧ សិក្ខាសាលាអនឡាញស្តីពី សវនកម្មសន្តិសុខព័ត៌មានវិទ្យា
- ៨ សិក្ខាសាលាស្តីពី ISQM1 ISQM2 និងISA 220
- ៩ សិក្ខាសាលាអនឡាញស្តីពី បញ្ហាប្រឈមនៃគណនេយ្យក្នុងវិស័យធនាគារ
- ១០ សិក្ខាសាលាស្តីពី ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៅកម្ពុជាលេខ15
- ១១ សិក្ខាសាលាអនឡាញស្តីពី បញ្ញាសិប្បនិម្មិតសម្រាប់វិស័យគណនេយ្យ និងសវនកម្ម
- ១២ សិក្ខាសាលាអនឡាញស្តីពី ការយល់ដឹងទៅលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អ្នកមិនហិរញ្ញវត្ថុ
- ១៣ សិក្ខាសាលាអនឡាញស្តីពី កោសល្យវិច័យគណនេយ្យ
- ១៤ សិក្ខាសាលាស្តីពី ស្តង់ដាគណនេយ្យពាក់ព័ន្ធនឹងធនាគារ និងមីក្រូហិរញ្ញវត្ថុ
- ១៥ សិក្ខាសាលាអនឡាញស្តីពី ពន្ធពន្យារ
- ១៦ សិក្ខាសាលាស្តីពី ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ16 អំពី ភតិសន្យា
- ១៧ សិក្ខាសាលាស្តីពី ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ17
- ១៨ សិក្ខាសាលាស្តីពី ស្តង់ដាសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនមានភាពស្មុគស្មាញ
- ១៩ សិក្ខាសាលាអនឡាញស្តីពី បច្ចុប្បន្នកម្មលើស្តង់ដាសវនកម្មអន្តរជាតិ IAS 2 IAS 12 និង IAS 21
- ២០ សិក្ខាសាលាអនឡាញស្តីពី សវកម្មពន្ធដារ
- ២១ សិក្ខាសាលាអនឡាញស្តីពី ពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ២២ សិក្ខាសាលាអនឡាញស្តីពី ពន្ធលើប្រាក់ចំណូល
- ២៣ សិក្ខាសាលាអនឡាញស្តីពី ពន្ធលើការបែងចែកភាគលាភ(កម្រិតខ្ពស់)
- ២៤ សិក្ខាសាលាស្តីពី ការលាងសម្អាតសាច់ប្រាក់ និងការផ្លាស់ប្តូររូបិយប័ណ្ណមុខងារ
- ២៥ សិក្ខាសាលាអនឡាញស្តីពី កិច្ចព្រមព្រៀងពន្ធត្រួតគ្នា
- ២៦ សិក្ខាសាលាអនឡាញស្តីពី កិច្ចគាំពារវិនិយោគិន និងច្បាប់ដែលមានជាធរមានក្នុងវិស័យមូលបត្រ
- ២៧ សិក្ខាសាលាអនឡាញស្តីពី បច្ចុប្បន្នភាពគណនេយ្យឆ្នាំ២០២៤
- ២៨ សិក្ខាសាលាស្តីពី សៀវភៅណែនាំលើការអនុវត្តការងារសវនកម្ម
- ២៩ សិក្ខាសាលាអនឡាញស្តីពី ការយល់ដឹងលើ IFRS 17
- ៣០ សិក្ខាសាលាអនឡាញស្តីពី ការយល់ដឹងជាទូទៅលើ IFRS S1 និង S2
- ៣១ សិក្ខាសាលាអនឡាញស្តីពី ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដោយផ្តោតលើអ៊ឹមភែរមិនលើទ្រព្យសកម្មហិរញ្ញវត្ថុ
- ៣២ សិក្ខាសាលាអនឡាញស្តីពី ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមដោយផ្តោតលើ
  - វិស័យធនាគារ
  - ភតិសន្យា
  - ពន្ធពន្យារ
  - ថ្លៃដើមនៃការខ្ចី
  - វិធីសាស្ត្រគន្លឹះក្នុងការអនុវត្ត
  - អ៊ឹមភែរមិន
  - ការលាតត្រដាងពន្ធលើប្រាក់ចំណូល
  - វិស័យកសិកម្ម
- ៣៣ សិក្ខាសាលាអនឡាញស្តីពី ការវាយតម្លៃលើការច្របាច់បញ្ចូលគ្នា និងការទិញយកអង្គភាព



# កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ

> “កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យថ្មីក្នុងប្រទេសកម្ពុជានឹងផ្តល់ឱកាសការងារដល់យុវជនកម្ពុជាដែលមានបំណងជ្រើសរើសជំនាញគណនេយ្យ”

ត្រូវបានអភិវឌ្ឍឡើងដោយ KICPAA ក្រោមការគាំទ្របច្ចេកទេសពី ICAEW និងឧបត្ថម្ភធនពី Russian Federation និង UNDP Cambodia ។ ATQ អាចជួយឱ្យនិស្សិតចំណាយពេលខ្លីក្នុងការសិក្សានិងអាចសិក្សានៅនឹងកន្លែងរបស់គេផ្ទាល់។ និស្សិតគ្រប់ទីកន្លែងនៅកម្ពុជាអាចសិក្សាជាមួយស្ថាប័នបណ្តុះបណ្តាលដែលជាដៃគូឬដោយខ្លួនឯងតាមរយៈកម្មវិធី LEARNING HUB ។

ATQ គឺជាកម្មវិធីប្រឡងសម្រាប់ការទទួលស្គាល់ ជំនាញគណនេយ្យកម្រិតបច្ចេកទេស។ ក្រោយពេលប្រឡងជាប់ពីរមុខវិជ្ជាដំបូងនិស្សិតនឹងក្លាយជាអ្នកកាន់បញ្ជីគណនេយ្យប្រកបដោយសមត្ថភាព ដែលមានតម្រូវការទីផ្សារការងារខ្ពស់។

## ហេតុអ្វីគួរជ្រើសរើស ATQ?

- ជាកម្មវិធីគណនេយ្យជំនាញដែលមានការទទួលស្គាល់
- អាចបត់បែនក្នុងការសិក្សា
  - សិក្សាដោយខ្លួនឯងតាមរយៈកម្មវិធី LEARNING HUB
  - សិក្សាជាមួយស្ថាប័នបណ្តុះបណ្តាលដែលជាដៃគូនៅកម្ពុជា
- អាចចុះកម្មសិក្សាជាមួយក្រុមហ៊ុនដែលជាសមាជិករបស់ KICPAA
- បន្ថែមគុណតម្លៃសម្រាប់អាជីពគណនេយ្យរបស់អ្នក
- មានឱកាសការងារខ្ពស់

## ឆ្ពោះទៅថ្ងៃអនាគត

- សុខដុមនីយកម្មនៃកម្មវិធីសិក្សាគណនេយ្យទូទាំងប្រទេសដែលអាចពង្រឹងដល់ប្រព័ន្ធអប់រំនៅកម្ពុជា
- បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់យុវជនដើម្បីត្រៀមខ្លួនក្នុងការប្រកបអាជីពនេះ
- ផ្តល់នូវសេវាកម្មគណនេយ្យប្រកបដោយទំនុកចិត្តនិងប្រកបដោយវិជ្ជាជីវៈដែលជួយដល់សេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅពេលអនាគត

រៀនតាមប្រព័ន្ធអនឡាញ គ្រប់ពេលវេលា គ្រប់ទីកន្លែង

រៀនជាភាសាខ្មែរ ឬអង់គ្លេស

មានបញ្ចូលនូវកម្មវិធីសិក្សា និងតេស្តសាកល្បងផ្សេងៗ

## កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ

**កម្រិតមូលដ្ឋានគ្រឹះ**

**ភាគ ១** – អ្នកកាន់បញ្ជីគណនេយ្យ
- TQ1: ការកាន់បញ្ជីគណនេយ្យ
- TQ2: បច្ចេកទេសកុំព្យូទ័រ និងកម្មវិធីសូហ្វវែគណនេយ្យ

**ភាគ ២** – គណនេយ្យករទទួលបន្ទុកថ្លៃដើម
- TQ3: ការសិក្សាអំពីការគណនាថ្លៃដើម
- TQ4: ការសិក្សាអំពីអាជីវកម្ម

**កម្រិតបច្ចេកទេស**

**ភាគ ៣** – គណនេយ្យករទទួលបន្ទុករៀបចំរបាយការណ៍
- TQ5: ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ
- TQ6: គណនេយ្យសម្រាប់ការគ្រប់គ្រង

**ភាគ ៤** – មន្ត្រីទទួលបន្ទុកផ្នែកច្បាប់និងពន្ធដារ
- TQ7: ពន្ធដារកម្ពុជា និងការអនុវត្ត
- TQ8: នីតិក្រុមហ៊ុន និងអាជីវកម្មកម្ពុជា

# សមាជិកជាប្រភេទក្រុមហ៊ុន

## សេវាកម្មគណនេយ្យ (សមាជិកសមាគត)

| ល.រ | ឈ្មោះក្រុមហ៊ុន | ទូរស័ព្ទ | អាសយដ្ឋាន |
|---|---|---|---|
| ១ | ជេភី-ខេមជីងហ្វៃ ខន់សាល់ធីង ឯ.ក | 093 371 790 | ផ្ទះលេខ 125J St.228 សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ភ្នំពេញ |
| ២ | វីចេង អ៊ិនវេសម៉ិន អេន ខនសាល់ធេន ឯ.ក | 086 76 75 84 | ផ្ទះលេខ 7B បន្ទប់លេខ 1&3 ផ្លូវ 81 កែង 109 ភូមិ 10 សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ |

@កក្កដា ២០២៤

## សេវាកម្មគណនេយ្យ (សមាជិកចូលរួម)

| ល.រ | ឈ្មោះក្រុមហ៊ុន | ទូរស័ព្ទ | អាសយដ្ឋាន |
|---|---|---|---|
| ១ | អ៊ែកសិទ្ធិ ខនសាល់ធីង ឯ.ក | 095 689 667 | ផ្ទះលេខ 25 ផ្លូវ 506 សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២ | អមត: ខនសាល់ធីង ឯ.ក | 085 991 109 | ផ្ទះលេខ64C ជាន់ទី3 ផ្លូវ348 សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៣ | អេស៊ាន ខេម អ៊ែត់វ៉ាយហ្ស៊ឺរ | 012 777 842 | ផ្ទះលេខ26 ផ្លូវ 610 ភូមិ 20 សង្កាត់បឹងកក់2 ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា |
| ៤ | អេស៊ានើរៀល អ៊ែត់វ៉ាយហ្ស៊ឺរ អ៊ីនឯ.ក | 017 229 722 | ផ្ទះលេខ 80F ផ្លូវ 210 សង្កាត់ទឹកល្អក់3 ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៥ | អ៊ែមខេម ខនសាល់ធីង | 093 980 180 | ភូមិវត្តស្វាយ សង្កាត់សាលាកំរើក ក្រុងសៀមរាប ប្រទេសកម្ពុជា |
| ៦ | អវតារ គ្លូបិល ហ្វាយនែន&អឹខោនធីង ហ្វឹម ឯ.ក | 012 772 771 | ផ្ទះលេខ18 ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ |
| ៧ | ប៊ី.អាយ.អេស អឹខោនធីង អេន តាក់ស៊ើវីស ឯ.ក | 098 893 999 | ផ្ទះលេខ 12B ផ្លូវលំ ភូមិដំណាក់ សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ ក្រុងភ្នំពេញ |
| ៨ | ប៊ីមីកស៍ ខនសាល់ធេន ឯ.ក | 092 564 416 | ភូមិតាប៉ូល សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប |
| ៩ | ប៊ូស៊ីនតាក់ ស៊ើវីស ឯ.ក | 085 360 111 | ផ្ទះលេខ 159C ផ្លូវ 36 Sony ក្រុម 2 ភូមិចុងថ្នល់កែង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ |
| ១០ | ខេមបូឌាន អ៊ិនវេសម៉ិន មេនេចម៉ិន អឹខោនធីង ស៊ើវីស ឯ.ក | 010 902 537 | ផ្ទះលេខ14 ផ្លូវលេខ106 ភូមិ 8 សង្កាត់ វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ១១ | ខេមវីន ហ្វាយនែនសល អ៊ែត់វ៉ាយហ្ស៊ឺរ ឯ.ក | 012 291 368 | ផ្ទះលេខ C8 ជាន់ទី១ ផ្លូវឈៀវហ្វូណេស សង្កាត់អូបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ |
| ១២ | ខេភីថេក ខនសាល់ធីង ស៊ើវីស ឯ.ក | 069 553 913 | ផ្ទះលេខSV35 ជាន់ផ្ទាល់ដី 8 បន្ទប់លេខ 806 ផ្លូវម៉ៅសេទុង ភូមិ9 សង្កាត់បឹងកេងកង1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| ១៣ | ឌី វ៉ែន អឹខោនធីង & ថេក ស៊ឺលូសិន ឯ.ក | 085 777 399 | S01 02 ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

| | | | |
|---|---|---|---|
| ១៤ | ឌីប៊ីអេ & អឹសូស៊ីអេត ឯ.ក | 069 505 999 | #អគារ Star City 2 ជាន់ទី 5 បន្ទប់លេខ 508 មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ |
| ១៥ | អ៊ី ប៊ី អិម ខូ អិលធីឌី | 023 213 919 | ផ្ទះលេខ 151 ជាន់ផ្ទាល់ដី និងជាន់ទី1 ផ្លូវ376 ភូមិ1 សង្កាត់បឹងកេងកង៣ បឹងកេងកង រាជធានីភ្នំពេញ |
| ១៦ | អ៊ីហ្គល ខេមបឹស ខនសាល់ធេន ឯ.ក | 077 392 074 | ផ្ទះលេខ 4C ផ្លូវចុះក្រោម ភូមិបេតុង ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ១៧ | អេវើខម ស៊ឺលូសិន ឯ.ក | 099 989 888 | ផ្ទះលេខ 163 ផ្លូវ 1015 (បុរីជីបម៉ុង) ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ១៨ | អេហ្វជីអេស ស៊ើវីស (ខេមបូឌា) ឯ.ក | 015 999 276 | ផ្ទះលេខ 09&10 ជាន់ផ្ទាល់ដី ផ្លូវ 250 ភូមិ1 សង្កាត់បឹងព្រលិត ខណ្ឌ7មករា រាជធានីភ្នំពេញ |
| ១៩ | ជី ដាប់បែលយូ ធី អេ ឯ.ក | 015 356 387 | ផ្ទះលេខ 8A ផ្លូវ 3BT ភូមិចំរើនផល សង្កាត់បឹងទំពុន1 ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ២០ | អេចធីផេក&អីខោនធីង ស៊ីលូសិន ឯ.ក | 087 621 199 | ផ្ទះលេខ 18 ផ្លូវបេតុង ភូមិព្រៃព្រីងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២១ | កម្ពុស៊ីណូ ជេ.អ៊ី ខនសាល់ធីង ឯ.ក | 012 859 812 | លេខ 01E0 ផ្លូវលេខ K4A សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ |
| ២២ | ខេឌី ខនសាល់ធេន ឯ.ក | 070 779 945 | ផ្ទះលេខ56 ផ្លូវ337 សង្កាត់បឹងកក់2 ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២៣ | កត់ត្រា អឹខោនធីង ឯ.ក | 023 232 456 | ផ្ទះលេខ 1346 ជាន់ទី1 ផ្លូវ371 ភូមិក្បាលទំនប់2 សង្កាត់បឹងទំពុន2 ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ២៤ | ឡា ប៉េ ផាតនើរ & អាសូស៊ីអេត ឯ.ក | 016 978 666 | ផ្ទះលេខ៨ ភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប |
| ២៥ | អិលអេចវ៉ាយ ស៊ីង យ៉ុង ឯ.ក | 012 682 983 | ផ្ទះលេខTRI5-91 បុរី អ័រគីដេ ផ្លូវដាលីយ៉ា ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ ក្រុងភ្នំពេញ |
| ២៦ | អិល ខេ អិន ជី ខនសាល់ធីង ឯ.ក | 010 814 499 | អគារ Time Square 2 បន្ទប់ D24 ជាន់ទី 24 ផ្លូវ 317 សង្កាត់បឹងកក់ទី 1 ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ២៧ | អឹម2អឹម ខនសាល់ធីង ស៊ើវីស ឯ.ក | 023 987 876<br>098 558 080 | #YUETAI ECC បន្ទប់លេខ 27M(1) នៃ 27M ជាន់ទី 27 មហាវិថីព្រះនរោត្តម ភូមិ 10 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២៨ | ម៉ៅរ៉ាខម ប៊ីហ្សនេស ឯ.ក | 012 708 505 | ផ្ទះលេខ 78 ជាន់ទី7 បន្ទប់7J ផ្លូវ95 ភូមិ3 សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២៩ | ហ្វីនិក ខនសាល់ធេសិន ស៊ើវីស ឯ.ក | 093 452 656 | ផ្ទះលេខK21 ផ្លូវ KJ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| ៣០ | រៀល ប៊ីហ្សនេស ខនសាល់ថេសិន | 012 273 276 | ផ្ទះលេខ D27 ផ្លូវ D, ភូមិក្បាលដំរី1 សង្កាត់កាកាប1 ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្ពុជា |
| ៣១ | រ៉ូយ៉ាល់ ខនសាល់ធីង | 023 232 889 | ផ្ទះលេខ 09 E0-E1 ផ្លូវ10 សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៣២ | រ៉ូយ៉ាល់ ស៊ីធីអេ (ខេមបូឌា) ខូ អិលធីឌី | 093 300 309 | ផ្ទះលេខ 20 (E1) ផ្លូវ 103R ភូមិទួលថ្នល់ សង្កាត់ទួលសង្កែ2 ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៣៣ | អេសឌី វីហ្សិន ខេម ឯ.ក | 087 334 888 | ផ្ទះលេខ TK រង្វង់មូល ជាន់ទី2 បន្ទប់ A2-01 ផ្លូវ 289 ភូមិ 12 សង្កាត់បឹងកក់ 2 ខណ្ឌទួលគោក រាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ៣៤ | ស្ទូ-លីង ខនសាល់ធីង សឺវីស ឯ.ក | 070 308 089 | Urban Village Building D ជាន់ទី 17 បន្ទប់លេខ 11 មហាវិថីសម្តេច ហ៊ុន សែន ភូមិព្រែកតានូ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៣៥ | អេសអេសភីអឹម ខនសាល់ធីង សឺវីស ឯ.ក | 011 880 226 | The Star City អគារលេខ2 ជាន់ទី 5 បន្ទប់លេខ503_2 មហាវិថីសហព័ន្ធរុស្ស៊ី(110) ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ |
| ៣៦ | អេសវីភីធី អឹខោនធីង សឺវីស ឯ.ក | 092 888 978 | ជាន់ផ្ទាល់ដី ផ្លូវសិរីភាព ភូមិ2 សង្កាត់4 ក្រុងព្រះសីហនុ |
| ៣៧ | ត្រាស់អេជ ខន់សាល់ធីង ឯ.ក | 089 592 001 | ផ្ទះលេខ7C2Eo ផ្លូលេខ01 ភូមិសំបូរ សង្កាត់ដង្កោ ខណ្ឌដង្កោ ភ្នំពេញ |
| ៣៨ | យូ.អេស.អេ.វី អ៊ិនធើណេសិនណល ប៊ីហ្សនេស ខនសាល់ធេនស៊ី ឯ.ក | 088 539 8888 | ផ្ទះលេខC46 & C48 បុរីអាកាសចរណ៍ ផ្ទះលេខ C50 មហាវិថីសហព័ន្ធរុស្ស៊ី ភូមិក្បាលដំរី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ |
| ៣៩ | វី-ហ្វីល ខនសាល់ធេន ឯ.ក | 098 414 515 | ផ្ទះលេខ834 ផ្លូវ BC ភូមិទួលថ្កាន សង្កាត់ទួលសង្កែ2 ឫស្សីកែវ ភ្នំពេញ |
| ៤០ | វេល ស្រ្ទធីជី អឹខោនធីង ឯ.ក | 087 727 373 | ផ្ទះលេខ 195 (បុរីភ្នំពេញថ្មី) ផ្លូវ 21 ភូមិបាយាប ក្រុងភ្នំពេញ |

@កក្កដា ២០២៤

## សេវាកម្មគណនេយ្យ (សមាជិកសកម្ម)

| ល.រ | ឈ្មោះក្រុមហ៊ុន | ទូរស័ព្ទ | អាសយដ្ឋាន |
|---|---|---|---|
| ១ | 3អេស ខនសាល់ធីង ឯ.ក | 087 552 035 | ផ្ទះលេខ 110 ផ្លូវ 06A ភូមិថ្មី ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២ | អាខ្លែម (ខេមបូឌា) ឯ.ក | 023 215 960<br>017 724 994 | ផ្ទះលេខ 1159មហាវិថីសម្តេច ហ៊ុន សែន ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៣ | ឌី អេ អេស & ផាតនើរ ឯ.ក | 012 252 413 | ផ្ទះលេខ6 ផ្លូវ474 ភូមិ7 សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៤ | ឌីជីធល ហ្វាយនែន ខនសាលធេនស៊ី ឯ.ក | 077 990 112 | 19&20 អគារ Exchange Square ជាន់ទី 14 បន្ទប់ 1431 ផ្លូវ 106 សង្កាត់វត្តភ្នំ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៥ | ហាន់ហ្គោ ស៊ូជី តាក់ & អឹខោនធីង (ខេមបូឌា) | 023 998 190<br>010 872 999 | អគារលេខ 216 បន្ទប់ Icon 39E1 មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៦ | អាយ គ្លោខល | 023 964 405 | ផ្ទះលេខ445 Phnom Penh Tower ជាន់ទី13 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលិត ខណ្ឌ7មករា រាជធានីភ្នំពេញ |
| ៧ | មេគង្គ អឹខោនធីង សឺវីស ឯ.ក | 069 690 613 | ផ្ទះលេខ 30 អគារ Bred Bank ជាន់ទី 4 ភូមិ 8 សង្កាត់ផ្សារថ្មី 3 ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៨ | ម៉េនុន & ផៃ អ៊ែត់វ៉ាយហ្ស៊ឺ ឯ.ក | 098 560 189 | ផ្ទះលេខ108 ផ្លូវលេខ97 ភូមិតាគុល សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប កម្ពុជា |
| ៩ | ស្កាយលីមីធីត អឹខោនធីង (ខេមបូឌា) ខូ អិលធីឌី | 092 786 541<br>092 786 540 | អគារ B-Ray (ជាន់ទី៨) ផ្ទះលេខ166 មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ១០ | វីឌីប៊ី ឡយ លីមីធីត | 023 964 430 | ផ្ទះលេខ 33 ផ្លូវលេខ 29 កែងផ្លូវលេខ 294 ភូមិ 4 ទន្លេបាសាក់ ចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

@កក្កដា ២០២៤

## សេវាកម្មគណនេយ្យ និងសវនកម្ម

| ល.រ | ឈ្មោះក្រុមហ៊ុន | ទូរស័ព្ទ | អាសយដ្ឋាន |
|---|---|---|---|
| ១ | អ៊ែតវ៉ានស៍ ហ្វ្រេន ហ្វ៊ូម៉ូឡា ឯ.ក | 085 368 888 | ផ្ទះលេខ 180 បុរីជីបម៉ុងរៀលផ្លូវP13 សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២ | អាល់នីសុន អឌីធីង អេន ខនសាល់ធីង | 023 222 123<br>088 77 66 865 | ផ្ទះលេខ ៥៤ ផ្លូវ ៣៥២ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| ៣ | អ៊ែមកល & ផាតនើរ (ខេមបូឌា) ឯ.ក | 016 595 856 | ផ្ទះលេខ26 (ជាន់ទី2) ផ្លូវលេខ 610,20 សង្កាត់បឹងកក់2 ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៤ | អេនឌ្រូ & ហ្វីលីព អ៊ីខោនធីង (អេ & ភី អ៊ីខោនធីង) | 023 964 999 | ផ្ទះលេខ 9E ផ្លូវ 608 សង្កាត់បឹងកក់ 2 ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៥ | អឹធឡូ អ៊ិនវេសម៉ិន & ខនសាល់ធីង ឯ.ក | 081 288 858 | ផ្ទះលេខ 120ZB ផ្លូវ 438 ភូមិ 04 សង្កាត់ទួលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៦ | អេ ភី វី (ខេមបូឌា) ខូ អិលធីឌី | 078 666 001<br>023 238 818 | លេខ 26B-95A-95B ផ្លូវ 320 សង្កាត់បឹងកេងកង I ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| ៧ | អឹសេន់អ៊ីខោនធីង អ៊ែរវ៉ាយហ្សឺរី ឯ.ក | 070 451 656 | ផ្ទះលេខ 3C2 ផ្លូវ516A ភូមិ1 បឹងកក់1ទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៨ | អេធី & អាសូស៊ីអេត | 023 212 616<br>012 92 31 75 | ផ្ទះលេខ 39C ផ្លូវ 155 សង្កាត់ទួលទំពូង1 ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៩ | អេធីអេភី & ផាតនើរ ឯ.ក | 023 233 868<br>016 646 344 | ផ្ទះលេខ 531 ផ្លូវ 128 ភូមិ 7 សង្កាត់ ផ្សារដេប៉ូ 1 ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ១០ | អាត្លាស ខនសាល់ធីង ឯ.ក | 089 666 383<br>092247555 | ផ្ទះលេខ 08 ផ្លូវ P-27 បុរី ប៉េងហួត ជឺស្តា ផ្លាទីនីម ប៉ូឡារីស II សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ១១ | អេ-អិចសីឡិន ខនសាល់ធេនស៊ី ឯ.ក | 016 268 689 | ផ្ទះលេខ 14 ផ្លូវ 02 សង្កាត់ទឹកល្អក់ 3 ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ១២ | បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក | 023 987100 | ផ្ទះលេខ 87B ផ្លូវ 294 សង្កាត់បឹងកេងកង1 ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ១៣ | បារុន (ខេមបូឌា) អ៊ីខោនធីង & ខនសាល់ធីង ឯ.ក | 096 661 2444 | អគារ SSN Center លេខ 66 បន្ទប់លេខ 03-04 (បន្ទប់ 303-A) ជាន់ទី 3 មហាវិថីព្រះនរោត្តម (41) ភូមិ៥ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ១៤ | បី ឌី អូ (ខេមបូឌា) លីមីធីត | 023 218 128 | ផ្ទះលេខ 28 សណ្ឋាគារកាំបូឌីយ៉ាណា ផ្លូវ 313 វិថីព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ |
| ១៥ | ប៊ីជី អាសូស៊ីអ៊ឹត | 023 218 426 | យូនីធី G33A02A Garden In The Air Tower ផ្លូវសុភ័ក្រមង្គល ទន្លេបាសាក់ រាជធានីភ្នំពេញ |
| ១៦ | ប៊្លូ ផាធើរ អ៊ីខោនថិន អេន អឌិតធ័រ ឯ.ក | 077 691 008 | ជាន់ទី1អគារ CPL ផ្លូវ 348 កែងផ្លូវ 205 សង្កាត់ទួលស្វាយព្រៃ2 ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ១៧ | ស៊ី អិម ប៊ី អេ ឯ.ក | 017 489 983 | ផ្ទះលេខ 689 A ជាន់ទី 2 ផ្លូវ 128 (មហាវិថីកម្ពុជាក្រោម) សង្កាត់ទឹកល្អក់ 1 ខណ្ឌទួលគោក ភ្នំពេញ |
| ១៨ | ខេម អ៊ីខោនធីង & ថាក ស៊ើវីស ឯ.ក | 089 777 589 | ផ្ទះលេខ 3D ផ្លូវ 416 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

| | | | |
|---|---|---|---|
| ១៩ | ស៊ី អេច អឹង អាសូស៊ីអេត ភីធីអ៊ី អិលធីឌី | (65) 96 694 540 | ផ្ទះលេខ 19 ផ្លូវ 730 សង្កាត់ផ្សារថ្មី ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២០ | ចន្ទ & អ៊ីសូស៊ីអេត | 095 555 188 | 7 ជាន់ (អគារអម្រឹត) ផ្ទះលេខ 80 ផ្លូវ 315 សង្កាត់បឹងកក់ 2 ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២១ | ក្រូវ (ខេអេច) ឯ.ក | 023 216 717<br>016 507 655 | Unit4B ជាន់ទី 4 អាគារ K1 #48 មហាវិថីម៉ៅសេទុង ផ្លូវ 245 សង្កាត់ទួលទំពូង 2 រាជធានីភ្នំពេញ |
| ២២ | ឌី ឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី | 023 963 777 | ជាន់ទី 8 Unit8 ផ្ទះលេខ 66 មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២៣ | ដូហូ ឆាធើរ អ៊ីខោនចិន (ខេមបូឌា) ឯ.ក | 017 295 577 | ផ្ទះលេខ 22&24 បន្ទប់លេខ202 ផ្លូវ281 ភូមិ14 សង្កាត់បឹងកក់1 ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ២៤ | ដូណាស្កូ & ខមភេនី អិលធីឌី | 023 997 830<br>012 896 486 | ផ្ទះលេខ 53 ផ្លូវលេខ446 ភូមិ 5 សង្កាត់ទួលទំពូង1 ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២៥ | អ៊ីស្ត វីង អឌីធីង និង ខនសាល់ធីង | 061 566 667 | ផ្ទះលេខ 108AB មហាវិថី ម៉ៅសេទុង (245) ភូមិ 2 សង្កាត់ទួលទំពូងទី2 ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២៦ | អេកូវីស វីអេសឌីខេ & ផាតនើរ ឯ.ក | 089 520 005 | ផ្ទះលេខ 17 ផ្លូវ 135 (កែង 500) ផ្សារដើមថ្កូវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២៧ | អ៊ីនស៍ អ៊ែន យ៉ាំង (ខេមបូឌា) | 023 217 824 | ជាន់ទី 5 Emerald Buidling ផ្ទះលេខ 64 មហាវិថីព្រះនរោត្តម កែងផ្លូវ 178 សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រទេសកម្ពុជា |
| ២៨ | ហ្វីដេស ស៊ីវីស (ខេមបូឌា) លីមីធីត | 023 217 307<br>012 880 920 | 3 ផ្លូវ 240 សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ២៩ | អេហ្សអាយអាយ &អ៊ីសូស៊ីអេត | 096 5551455<br>023 555 1455 | អាគារ C7 ផ្លូវវិមានអហារ ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ |
| ៣០ | ហ្គូមី & ផាតនើរ ឯ.ក | 023 926 999<br>070 465 777 | ផ្ទះលេខ១២ ផ្លូវ៣៤៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៣១ | ហ្គូណន ខនសាល់ធីង ឯ.ក | 069 923 337 | អគារ PPIU ផ្ទះលេខ36 ជាន់ទី9 ផ្លូវ169 សង្កាត់វាលវង់ ខណ្ឌ7មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ៣២ | ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត | 023 966 520<br>010 58 59 60 | អគារកាណាឌីយ៉ា ជាន់ទី២០ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៣៣ | អេចអិលប៊ី អឌីត & ផាតនើរ ឯ.ក | 077 92 42 80 | អាគារ ឡាយ អាន ផ្ទះលេខ 123 ផ្លូវ 192 សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៣៤ | ខេ ប្រ៊ី ហ្វេសិនណល អ៊ីខោនចិន | 099 554 445 | ជាន់ទី៥ អគារ CPL សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៣៥ | ខេ ភី អឹម ជី ខេមបូឌា | 017 666 537<br>078 786 680 | ជាន់ទី 35 អគារ GIA ផ្លូវសុភមង្គល ភូមិ 14 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៣៦ | ឡូចន្ទ & ខូ (ខេមបូឌា) ឯ.ក | 023 211 541<br>070 228 907 | អគារ Morgan Tower ជាន់ទី8 បន្ទប់លេខ 8F-01/17B សុភមង្គល ភូមិ 14 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា |
| ៣៧ | អិលអេស ហេនឌើសិន (ខេមបូឌា) | 092 382 555 | ផ្ទះលេខ 121 ជាន់ទី 1 មជ្ឈមណ្ឌលភ្នំពេញ មហាវិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៣៨ | ម៉ូរីសុនកាក់ អិមខេអេ អឌីត-អ៊ីខោនធីង ឯ.ក | 077 38 82 82 | ផ្ទះលេខ 10 ផ្លូវ 500 សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ៣៩ | អិន អេ អេស | 012 786 971 | ផ្ទះលេខ 431 ( 7 ជាន់ ) ផ្លូវ 230 សង្កាត់ទឹកល្អក់ 3 ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៤០ | ញូ សាញ ខនសាល់ធីង ឯ.ក | 089 792 795 | ផ្ទះលេខ445 Phnom Penh Tower មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលិត ខណ្ឌ7មករា រាជធានីភ្នំពេញ កម្ពុជា |
| ៤១ | ភី អេ ធី ប្រីហ្វេសិនណល លីមីធីត | 023 967 156<br>098 951 156 | Olympia City អគារ C7 ជាន់ទី 8 បន្ទប់ 817-818 ផ្លូវឧកញ៉ាទេពផន ( 182 ) កែង ( 161 ) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៤២ | ផេក ខនសាល់ធីង ឯ.ក | 017 666 078 | បុរីប៉េងហួត Residence ផ្ទះលេខ 41 បន្ទប់ P1 ផ្លូវ R02 បឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៤៣ | ហ្វីនិក អឹខោនធីង ( ខេមបូឌា ) ឯ.ក | +65 8339 1766 | អគារលេខ315 ជាន់ទី18 មហាវិថី ព្រះមុនីវង្ស កែងផ្លូវ អង្គឌួង 1 វត្តភ្នំ ដូនពេញ រាជធានីភ្នំពេញ កម្ពុជា |
| ៤៤ | ភីខេអេហ្វ ខូវេណិនថ៍ ឯ.ក | 023 884 138<br>081 686 226 | ផ្ទះលេខ 689A មហាវិថីកម្ពុជាក្រោម ( 128 ) សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៤៥ | ប្រាយវ៍តធ័រហោវខូភើស៍ ( ខេមបូឌា ) | 023 860 606<br>012 510 111 | ផ្ទះលេខ58 មហាវិថីព្រះសីហនុ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៤៦ | ខ្វនចឹម & ស្ពេកត្រឹម ឯ.ក | 012 228 069 | ផ្ទះលេខ 44 ជាន់ទី 1 ផ្លូវ 1956 ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ |
| ៤៧ | រីចង៍ & ផាតនើរ | 023 230 333<br>011 210 348 | ផ្ទះលេខ 2283 ផ្លូវ 1970 ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៤៨ | រីនដា អិល អិល ខេ ជី ( ខេមបូឌា ) | 023 222 182 | បន្ទប់លេខ 2255 នៃផ្ទះលេខ 54 ផ្លូវ 352 S/K បឹងកេងកង I ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៤៩ | រ៉ូសូខូ លីមីធីត | 012 78 97 65<br>023 212 280 | ផ្ទះលេខ08 ផ្លូវលេខ492 ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា |
| ៥០ | សំរិទ្ធិ អឹខោនធីង អេន មេនេចមិន ឯ.ក | 095 333 799 | ផ្លូវកែវចិន្ដា មហាវិថី មេគង្គ៦ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ |
| ៥១ | អេសស៊ីអេស គ្លូបិល ខនសាល់ធីង ( ខេមបូឌា ) | 023 901 125<br>010 294 523 | ផ្ទះលេខ 515 ជាន់ទី1 ( បន្ទប់ 103 ) មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៥២ | អេស អិម គ្លូបិល អឹខោនធីង & ខនសាល់ធីង | 023 990 853<br>076 899 0853 | អាគារលេខ៥៣ បន្ទប់លេខ២៣ មហាវិថីព្រះមុនីវង្ស ភូមិ០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៥៣ | សឡឹមិន អឹខោនធីង ខនសាល់ធីង | 023 99 88 44<br>012 241 000 | ផ្ទះលេខ 148 អគារK1ជាន់ទី10 មហាវិថីម៉ៅសេទុង សង្កាត់ទួលទំពូង2 ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៣៤ | ថៃ អេន ឡេា មេនេចមិន ខនសាល់ធេន ឯ.ក | 023 882 152<br>012 661 166 | ផ្ទះលេខ949 ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៥៥ | វីប៊ីធី អេន ផាតនើរ ឯ.ក | 012 268 816 | ផ្ទះលេខ 76E0 ផ្លូវ 20 ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ៥៦ | វី ឆាធើរ អឹខោនថិន | 023 985 468 | Phnom Penh Centre បន្ទប់លេខ 482 ជាន់ទី 4 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៥៧ | វ៉ូរី អេខោនធីង ( ខេមបូឌា ) ឯ.ក | 023 223 878 | លេខ 254 អគារIOC មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា |
| ៥៨ | យ៉ុងអាន អ៊ិនធើណេសិនណល ខនសាល់ធីង ឯ.ក | 088 716 2158 | បន្ទប់លេខ 907 ជាន់ទី 9 នៃអគារ Carnation ផ្លូវលំ ភូមិទំនប់1 សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

# សមាជិកជា ប្រភេទបុគ្គល

| សមាជិកជាប្រភេទក្រុមហ៊ុន | សមាជិកជាប្រភេទបុគ្គល | សមាជិកបម្រុង |
| --- | --- | --- |

សូមបញ្ចូលឈ្មោះសមាជិកណាមួយ ជាភាសាអង់គ្លេស ដើម្បីស្វែងរកសមាជិកជាប្រភេទបុគ្គល។

នាមឈ្មោះ

នាមត្រកូល

ស្វែងរកសមាជិក

- សមាជិកកិត្តិយស
- សមាជិកសកម្ម
- សមាជិកចូលរួម
- សមាជិកសមាគត
- សមាជិកបម្រុង




សូមចុចលើ link ខាងក្រោមសម្រាប់ព័ត៌មានលម្អិតបន្ថែម

https://www.kicpaa.org/en/membership/member-directory/

## ទំនាក់ទំនងមក វ.គ.ស.ក.

| WEBSITE | TELEGRAM | FACEBOOK PAGE | DOWNLOAD IT TODAY ON: |
|---|---|---|---|
| | | | Download on the App Store<br>GET IT ON Google Play |

សម្រាប់ការសាកសួរអំពីតម្រូវការសមាជិកភាព
សូមមេត្តាទាក់ទងមកយើងខ្ញុំតាមរយៈ៖
ទូរស័ព្ទ៖ 077 241 707
អ៊ីមែល៖ membership@kicpaa.org

សម្រាប់ការសាកសួរអំពីកម្មវិធីសិក្សាបច្ចេកទេស
គណនេយ្យ សូមមេត្តាទាក់ទងមកយើងខ្ញុំតាមរយៈ៖
ទូរស័ព្ទ៖ 017 493 140
អ៊ីមែល៖ atq@kicpaa.org

ទូរស័ព្ទ៖ 023 23 17 07 | អ៊ីមែល៖ kicpaa@kicpaa.org | គេហទំព័រ៖ www.kicpaa.org
អាសយដ្ឋាន៖ ជាន់ទី ៨ អគារ វីត្រាស់ ផ្លូវ ១៦៩ សង្កាត់ វាលវង់ ខណ្ឌ ៧ មករា
រាជធានីភ្នំពេញ កម្ពុជា

# Study online anytime anywhere

# Khmer and English available




## DOWNLOAD IT TODAY ON:

Download on the App Store

GET IT ON Google Play

(+855) 23 23 17 07 | kicpaa@kicpaa.org | www.kicpaa.org

kicpaacambodia | kicpaa | 077 241 707/017 493 140